00747591

E116/1/2

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 13 / 10 / 2011
ម៉ោង (Time/Heure) : 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សម្ងាត់ / Confidential / Confidentiel

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ: សាធារណៈ / Public 31/01/2012

ឈ្មោះមន្ត្រីដែលបានពិនិត្យ: Peang Tola

ហត្ថលេខា: [signature]

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលកំណត់ដើម្បីឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខផ្សេងៗរបស់ នួន ជា ជំទាស់នឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | **អង្គជំនុំជម្រះតុលាការកំពូល:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រ៊ឹម, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Motoo NOGUCHI | អៀង សារី |
| | ចៅក្រម សោម សិរីវឌ្ឍ | អៀង ធីរិទ្ធ |
| | ចៅក្រម A. KLONOWIECKA-MILART | ខៀវ សំផន |
| | ចៅក្រម ម៉ុង មុនីចរិយា | |
| | ចៅក្រម C. N. JAYASINGHE | **មេធាវីការពារក្ដីជនជាប់ចោទ:** |
| | ចៅក្រម យ៉ា ណារិន | លោក សុន អរុណ |
| | សហមេធាវីនាំមុខតំណាងដើមបណ្ដឹង | លោក Michiel PESTMAN |

E116/1/2

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក*

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក Victor Koppe |
| | លោក អាង ឧត្តម |
| ពេជ អង្គ | លោក Michael G.KARNAVAS |
| Elisabeth SIMONNEAU FORT | លោក ផាត់ ពៅសៀង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

E116/1/2

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក*

**សំណើ**

១. នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ("មេធាវីការពារក្តី") បានដាក់ *បណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ* ("បណ្តឹងសាទុក្ខ")[1]។ យោងតាមស្តង់ដារនៃក្របខ័ណ្ឌពេលវេលាសម្រាប់ការដាក់ចម្លើយតប ដែលមានចែងកំណត់នៅក្នុងសេចក្តីណែនាំអនុវត្តសម្រាប់ការដាក់ឯកសារចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខនេះ ត្រូវផុតកំណត់ត្រឹមថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១ គឺមានរយៈពេលចំនួន១០(ដប់)ថ្ងៃ គិតពីថ្ងៃជូនដំណឹងនៃបណ្តឹងសាទុក្ខនេះ។

២. ដោយអនុលោមតាមវិធាន ៣៩.៤ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា ("កសព") សូមស្នើសុំពន្យាពេលដើម្បីដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខនេះ រហូតដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលជាការពន្យារពេលចំនួន២០ថ្ងៃនៃប្រតិទិន។ ការពន្យារពេលគឺជាការចាំបាច់ក្នុងគោលបំណង ដើម្បីឱ្យសហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបមួយដោយមានសំអាងហេតុដ៏ល្អ និងយ៉ាងទូលំទូលាយ ចំពោះបញ្ហានានាខាងអង្គហេតុ និងខាងអង្គច្បាប់ដ៏ស្មុគស្មាញ ដែលបានលើកឡើងនៅក្នុង បណ្តឹងសាទុក្ខនេះ។ ដោយឡែក បណ្តឹងសាទុក្ខនេះ មានដាក់បញ្ចូលនូវការយោងទៅលើបញ្ហា ទាំងឡាយខាងអង្គហេតុដែលមានៅក្នុងឈុតនានានៃសំណើ ពាក្យសុំ ការជំទាស់ និង បណ្តឹង ឧទ្ធរណ៍ ដែលបានដាក់ក្នុងចន្លោះខែមីនា ឆ្នាំ២០០៩ និង ខែមេសា ឆ្នាំ២០១១។ ចម្លើយតបដែល មានអត្ថន័យគ្រប់គ្រាន់មួយទៅនឹងបណ្តឹងសាទុក្ខនេះ នឹងតម្រូវឱ្យមានការចាំបាច់ពិនិត្យសារជាថ្មី ឡើងវិញនូវបញ្ហានានាខាងអង្គហេតុដែលមាននៅក្នុងសេចក្តីសន្និដ្ឋានទាំងនេះពីមុនៗ ដែលជាការ បន្ថែមទៅនឹងការវិភាគ និងការឆ្លើយតបនានាទៅនឹងអំណះអំណាងខាងផ្លូវច្បាប់ដែលមានបញ្ជាក់នៅក្នុងបណ្តឹងសាទុកនេះ។ សម្រាប់រឿងនេះ វាគ្រាន់តែជាការមួយដែលមិនប្រាកដប្រជាតែ ប៉ុណ្ណោះ បើគេធ្វើវាក្នុងរយៈពេលចំនួន១០ថ្ងៃ ដោយរួមទាំងពេលវេលាបកប្រែភាសាផងនោះ ។

[1] **E116/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួនប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ១០ តុលា ២០១១ ("បណ្តឹងសាទុក្ខរបស់ នួន ជា"), ដែលបានជូនដំណឹងដល់គូភាគីនានានៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ។

00747594

E116/1/2



៣. សហព្រះរាជអាជ្ញា កត់ធ្វើការសំគាល់បន្ថែមទៀតថា ដោយសារតែបណ្តឹងសាទុក្ខមិនមានអានុភាព បង្អង់ដោយស្វ័យប្រវត្តិនូវដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ០០២ នោះ[2] គឺវាមិនធ្វើឱ្យមានការខូចខាតណាមួយដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ ដែលជាលទ្ធផលបណ្តាលមកពីការពន្យារពេលកំណត់ ដើម្បីឱ្យសហព្រះរាជអាជ្ញាដាក់នូវចម្លើយតបរបស់ខ្លួននេះឡើយ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០១១ | **លោកស្រី ជា លាង**<br>**សហព្រះរាជអាជ្ញា** | ភ្នំពេញ | |
| | **លោក** William SMITH<br>**សហព្រះរាជអាជ្ញារង** | | |

[2] វិធាន១០៤ នៃវិធានផ្ទៃក្នុងចែងថា "[] លើកលែងតែមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬការសំរេចផ្សេងដោយអង្គជំនុំជម្រះសាលាដំបូង បណ្តឹងសាទុក្ខភ្លាមៗមិនអាចមានអានុភាពបង្អង់នីតិវិធីនៅមុខអង្គជំនុំជម្រះសាលាដំបូងទេ" ។